ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី០៦របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩

រៀបចំដោយ: នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី០៦ សម្រាប់ឆ្នាំ២០១៩ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍និងជំងឺអេដស៍។កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-បទបង្ហាញពីរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញលទ្ធផលបឋមនៃការសិក្សា ស្តីពីសន្ទស្សន៍នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ ឆ្នាំ២០១៩ ( Stigma Index 2:0, 2019 )

-និងបញ្ហាផ្សេងៗ

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។






**ប្រធានបទទី១**:

បទបង្ហាញពីរបាយការណ៍សកម្មភាព និងលទ្ធផលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំខែកក្កដា ឆ្នាំ២០១៩ ដោយ **លោកវេជ្ជបណ្ឌិត លី ចាន់រ៉ាឌុច** អនុប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖



**ក- សកម្មភាព និងលទ្ធផលសម្រេចបាន៖**

- ✓ ថ្ងៃទី២-៤ ខែកក្កដា ឆ្នាំ២០១៩ មន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់ធ្វើការងារជាមន្ត្រីអនុវត្តច្បាប់ក្នុងការទប់ស្កាត់ការឆ្លើយតបទៅនឹងអំពើហឹង្សាប្រឆាំងនឹងក្រុមប្រឈម ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាច្បាប់ និងពង្រឹងការឆ្លើយតបចំពោះមេរោគអេដស៍ នៅសណ្ឋាគារភ្នំពេញ ។
- ✓ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩ បានផ្សព្វផ្សាយពីស្ថានភាពបច្ចុប្បន្ន និងវិធីបង្ការការឆ្លងមេរោគអេដស៍ ដល់នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃអង្គភាពបញ្ជូនសារអគ្គបញ្ជាការ ដែលមានអ្នកចូលរួមចំនួន ២១០នាក់។
- ✓ ថ្ងៃទី១៥-១៦ ខែកក្កដា ឆ្នាំ២០១៩ បានបើកវគ្គបណ្តុះបណ្តាលដល់បុគ្គលិកបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្តីពីការអនុវត្ត និងប្រើប្រាស់ទិន្នន័យស្តីពីការអង្កេតការចំណាយលើការងារប្រយុទ្ធនឹងជំងឺអេដស៍ (NASA) នៅសណ្ឋាគារភ្នំពេញ ដែលរៀបចំដោយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ។
- ✓ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ឯកឧត្តមអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានផ្សព្វផ្សាយអប់រំពីបច្ចុប្បន្នភាព និងការបង្ការការឆ្លងមេរោគអេដស៍ ដល់នាយទាហាន នាយទាហានរង និងពលនាវីទាំងអស់នៃបញ្ជាការដ្ឋានការពារកោះឆ្នេរនាខេត្តព្រះសីហនុ ដែលមានអ្នកចូលរួមចំនួន ៤៧២នាក់។
- ✓ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមបើកវគ្គកិច្ចសន្ទនាស្តីពីបញ្ឈប់ការរើសអើងជនរងគ្រោះដោយសារគ្រឿងញៀន និងផ្តល់ការគាំទ្រទៅរកសេវាសុខភាព ដែលរៀបចំដោយអង្គការ KHANA នៅភោជនីយដ្ឋានទន្លេបាសាក់២។

- ✓ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំកិច្ចប្រជុំក្រុមការងារ Steering Committee ដើម្បីពិនិត្យសេចក្តីព្រាងចុងក្រោយរបស់ផែនការយុទ្ធសាស្រ្តជាតិលើកទី៥ សម្រាប់ឆ្នាំ២០១៩-២០២៣។
- ✓ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩តំណាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមជាមួយក្រសួងបរិស្ថាន ដើម្បីរៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយពីគ្រឿងញៀន និងជំងឺអេដស៍ ដែលបានប្រព្រឹត្តទៅនៅខេត្តព្រះវិហារ ។
- ✓ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងជ្រើសរើសសារសម្រាប់ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៩។
- ✓ នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវកំពុងរៀបចំរបាយការណ៍ប្រចាំឆមាសទី១ ប្រចាំឆ្នាំ២០១៩។
- ✓ នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ កំពុងពិនិត្យមើលសេចក្តីព្រាងរបាយការណ៍ស្តីពីការអង្កេតការចំណាយប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៦-២០១៧ ( NASA Report )។

**ខ- សកម្មភាពបន្ត៖**

- ✓ បន្តការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ សម្រាប់ឆ្នាំ២០១៩-២០២៣។ បញ្ចប់សេចក្តីព្រាង និងប្រជុំពិគ្រោះយោបល់។
- ✓ បញ្ចប់របាយការណ៍ការអង្កេតជាតិស្តីពីការចំណាយថវិកាក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ឆ្នាំ២០១៦-២០១៧ ( NASA Report 2016-2017 )។
- ✓ បានបញ្ចប់របាយការណ៍ នៃការសិក្សាស្តីពីសន្ទស្សន៍នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ឆ្នាំ២០១៩ ( Stigma Index 2:0, 2019 ) រៀបចំសិក្ខាសាលាពិគ្រោះយោបល់និងផ្សព្វផ្សាយ។
- ✓ បន្តការងារអនុវត្ត ស.ជ.ណ លេខ២១៣ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធស្របតាមលទ្ធផលកិច្ចប្រជុំអន្តរក្រសួងកាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។
- ✓ បន្តការងារការបង្កបរិយាកាសគាំទ្រផ្លូវច្បាប់ គោលនយោបាយ កម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានអនុវត្តកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

- តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច: សម្រាប់ខែកក្កដានេះ ពុំបានផ្សព្វផ្សាយច្បាប់អេដស៍ដោយផ្ទាល់ទេ តែបានបញ្ជ្រាបសារមួយចំនួនទាក់ទងទៅនឹងបញ្ហាអេដស៍ នៅក្នុងវេទិការគ្រឿងញៀន និងច្បាប់ចរាចរណ៍ផ្លូវគោក ដល់ស្រុកគោលដៅចំនួន៥ ក្នុងខេត្តតាកែវបាន២វគ្គនិងខេត្តបាត់ដំបង បាន៣វគ្គ ដោយមានអ្នកចូលរួមចំនួន១៧៩២នាក់ ស្រីចំនួន៨១៩នាក់។
- តំណាងក្រសួងអប់រំ យុវជន និងកីឡា: មានកញ្ចប់ថវិកាសម្រាប់ឆ្នាំ២០២០ លើការងារអេដស៍ តែដាក់ថាសកម្មភាពអប់រំ បង្ការគ្រឿងញៀន មេរោគអេដស៍ និងជំងឺអេដស៍ និងគ្រោះថ្នាក់ចរាចរណ៍។ ទាក់ទងទៅនឹងកម្មវិធីសិក្សា ក្រសួងបានកែទម្រង់ការសិក្សាថ្មី ឱ្យយុវជនក្លាយជាយុវជនសតវត្សទី២១ ហើយសាលារៀន និងលោកគ្រូ អ្នកគ្រូ ក៏សតវត្សទី២១ដែរ។ ចំណែកមេរៀនអប់រំសុខភាព គឺមាន១ម៉ោង ក្នុង១សប្តាហ៍ ហើយបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ គឺបញ្ចូលពីថ្នាក់ទី៥ ដល់ទី១២។
- តំណាងក្រសួងកិច្ចការនារី: ពីថ្ងៃទី១០-១២ខែកក្កដា ឆ្នាំ២០១៩ នាយកដ្ឋានស្ត្រី និងសុខភាព បានរៀបចំវេទិការ៣វគ្គ ស្តីពីសុខភាពបន្តពូជ ការការពារមេរោគអេដស៍ និងជំងឺអេដស៍ និងអាហារូបត្ថម្ភ ដើម្បីបង្កើនការយល់ដឹងដល់ប្រជាជនគោលដៅ បានធ្វើនៅស្រុកអង្គរជុំ ខេត្តសៀមរាប ដោយមានអ្នកចូលរួមចំនួន៤៥៧ នាក់ ស្រីចំនួន២៦៥នាក់។

**ប្រធានបទទី២**: បទបង្ហាញពីលទ្ធផលបឋមនៃការសិក្សា ស្តីពីសន្ទស្ស នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ ឆ្នាំ២០១៩ (Stigma Index 2:0, 2019) បង្ហាញជូនដោយ **លោកវេជ្ជ. ស៊ឹម ស្វៃ** នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវៈ

- ✓ សាវតានៃការសិក្សាៈ បានធ្វើលើកទី១ នៅឆ្នាំ ២០១០ និងលើកទី២ នៅឆ្នាំ២០១៨-២០១៩
- ✓ ការរៀបចំការសិក្សាៈ
    - លក្ខខណ្ឌជ្រើសរើស
        - អាយុចាប់ពី១៨ ឆ្នាំ
        - ដឹងស្ថានភាពខ្លួនឯង មានផ្ទុកមេរោគយ៉ាងតិច១២ខែ
        - មានសុខភាពផ្លូវចិត្តគ្រប់គ្រាន់
        - ចូលរួមក្នុងការសិក្សាដោយស្ម័គ្រចិត្ត និង

- ចេះនិយាយភាសាខ្មែរ

- របៀបនៃជ្រើសរើស
  - ការជ្រើសរើសតាមបញ្ជី ដោយតាមការចៃដន្យ
  - ការជ្រើសរើសតាមគ្លីនិក
  - ការជ្រើសរើសតាម Snowball
- រយៈពេលប្រមូលៈ ពីថ្ងៃទី៨ ខែមករា ដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩
- ចំនួនសំណាកៈ 1222 /1200 សំណាកគោលដៅ ដោយធ្វើនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកណ្តាល និងខេត្តកំពង់ចាម។

✓ ការសន្និដ្ឋានៈ

- ជាទូទៅការមាក់ងាយ និងរើសអើងពីខាងក្រៅ មានកម្រិតតិចតួច ប៉ុន្តែការមាក់ងាយ និងរើសអើងដោយខ្លួនឯង នៅមានកម្រិតខ្ពស់នៅឡើយ។
- អ្នកផ្ទុកមេរោគអេដស៍ មានការយល់ដឹងពី viral load suppression និងច្បាប់អេដស៍ នៅមានកម្រិតនៅឡើយ។
- ជាទូទៅស្ថានភាពសុខភាព អ្នកផ្ទុកមេរោគអេដស៍ មានស្ថានភាពល្អ និងមធ្យម តែសុខភាពផ្លូវចិត្តពួកគាត់នៅតែជាបញ្ហាប្រឈមនៅឡើយ។
- ការគាំពារសង្គម ចំពោះអ្នកផ្ទុកមេរោគអេដស៍ បានដំណើរការនៅសហគមន៍ ប៉ុន្តែការទទួលបាននូវ ID Poor cards នៅកម្រិតនៅឡើយ។
- ជាទូទៅការទទួលនូវភាពអវិជ្ជមានពីអ្នកផ្តល់សេវា នៅសេវាថែទាំជំងឺអេដស៍មានកម្រិតតិចតួចបំផុត ដូចការបង្ហាញពីស្ថានភាពរបស់អ្នកផ្ទុកមេរោគអេដស៍។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានស្នើដល់សមាជិក សមាជិកា ចូលរួមយោបល់ដូចខាងក្រោម៖

✓ តំណាងក្រសួងអប់រំ យុវជន និងកីឡាៈ ការបង្ហាញដាក់ថា ការសិក្សាទៅលើការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ តែដល់ការបង្ហាញគឺធំទូលំទូលាយជាងការរើសអើងទៅទៀត និងការប្រើពាក្យ (នៅមានកម្រិត) គួរប្រើពាក្យនៅមានកម្រិតខ្ពស់ ឬកម្រិតទាប។

✓ ឯកឧត្តមប្រធានអង្គប្រជុំៈ ការធ្វើ Survey គឺការអង្កេតដោយប្រើវិធីសាស្ត្របែបបរិមាណ និងធ្វើរបៀបជ្រើសរើសដោយចៃដន្យ តែបែរជាប្រើវិធីសាស្ត្រ Snowball ដែលជាវិធីសាស្ត្រ ប្រើប្រាស់នៅក្នុង qualitative method សម្រាប់ hard to reach population ដែលគួរពិចារណា ឬអ្នក

ធ្វើអាចមានហេតុផលផ្សេងពីនេះ។ ការធ្វើតារាងល្អ គឺគេមិនដែលដាក់ភាគរយ និងចំនួននៅក្បែរគ្នាទេព្រោះធ្វើឱ្យគេច្រឡំ ហើយក្នុងតារាងមួយគួរបង្ហាញតែមួយរឿងបានហើយ។ ការសិក្សាស្តីពីសន្ទស្សន៍នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ (Stigma Index) តើយើងរកឃើញ Stigma យ៉ាងម៉េច? Discriminate យ៉ាងម៉េច? ភាគច្រើនគឺបញ្ចូលគ្នា ដែលធ្វើឱ្យមានការភ័ន្តច្រឡំដែលគួរពិចារណា។ ការប្រើពាក្យ Stigma និង Discriminate ពិបាកណាស់ ហើយក្រុមគោលដៅសុទ្ធតែពុំមានការអប់រំខ្ពស់ ដែលធ្វើឱ្យពួកគាត់មានការយល់ច្រឡំ ដោយយល់ពុំបានច្បាស់ ដូចនេះពួកគាត់ឱ្យទិន្នន័យពុំច្បាស់ដល់ការស្រាវជ្រាវ គួរតែធ្វើ pre test អំពីភាសាដើម្បីឱ្យពួកគាត់បានយល់ នោះយើងនឹងទទួលបានទិន្នន័យច្បាស់លាស់។

- ✓ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: ចំពោះបញ្ហា ID Poor ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការកែសម្រួល Guideline របស់មូលនិធិសមធម៌ ជាពីរដំណាក់កាល។ ដំណាក់កាលទី១ គឺធ្វើ Guideline ឱ្យគ្របដណ្តប់លើអ្នកជំងឺអេដស៍ក្រីក្រ ដោយសព្វថ្ងៃប្រើមូលនិធិសមធម៌ (Health Equity Fund) ហើយដំណាក់កាលទី២ ចាប់ពីឆ្នាំ 2021-2023 នឹងជជែកជាមួយមូលនិធិសកល ដើម្បីឱ្យមូលនិធិសមធម៌បានគ្របដណ្តប់ទៅលើអ្នកជំងឺអេដស៍ទាំងអស់។

ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបជូនដល់សមាជិក សមាជិកានៃអង្គប្រជុំថា <u>**កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៧ នឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៤ ខែសីហា ឆ្នាំ២០១៩**</u> ដែលក្រុមការងារនឹងជម្រាបជូននៅពេលក្រោយ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង៣០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**<u>ឧបសម្ពន្ធ៖</u>**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃអង្គារ ១៤រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩

**បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់**
** អគ្គលេខាធិការ**

**វេជ្ជ. ហោ ប៊ុនឡេង**

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋាន
ទាក់ទង និងចលនាប្រភពធនធាន

**វេជ្ជ. ឈា សិទ្ធិ**

**អ្នកធ្វើរបាយការណ៍**

**វេជ្ជ. ហេង ហៃ**

16 . 8 . 19